ក្រុមប្រឹក្សារដ្ឋ
លេខ ០៤ ក្រ.ច

**សាធារណរដ្ឋប្រជាមានិតកម្ពុជា**
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

# ក្រឹត្យ-ច្បាប់
## ស្តីពី
## បទល្មើសមានលក្ខណៈយោធា និងទណ្ឌកម្ម
## ក្រុមប្រឹក្សារដ្ឋ

បានឃើញរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

ដើម្បីការពារសន្តិសុខ ការពារប្រទេស ការពារកម្លាំងប្រយុទ្ធរបស់កងកម្លាំងប្រដាប់អាវុធប្រជាជនបដិវត្តកម្ពុជា ពង្រឹងវិន័យរបស់កងទ័ព និងការពារនីត្យានុកូលភាព ។

តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារប្រទេស និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ក្រុមប្រឹក្សារដ្ឋមន្ត្រីយល់ព្រមផង ។

**<u>សម្រេច</u>**

**មាត្រា ១** គោលការណ៍បង្ក្រាបបទល្មើស ។

គ្រប់អំពើល្មើស ដែលធ្វើអោយប៉ះពាល់ដល់កម្លាំងប្រយុទ្ធ របស់កងកម្លាំងប្រដាប់អាវុធប្រជាជនបដិវត្តកម្ពុជា និង ដល់បទបញ្ជានៃបរិចារកិច្ចយោធ ត្រូវរកអោយឃើញទាន់ពេលវេលា និងផ្តន្ទាទោសតាមសមធម៌ ។

អំពើញុះញង់ ឬ ជំរុញជនច្រើនរូបអោយប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយត្រូវផ្តន្ទាទោសជាទម្ងន់ ។ អំពើដែលបណ្តាលអោយមានការខូះខាតធ្ងន់ធ្ងរ ឬ ធ្វើអោយប៉ះពាល់ជាខ្លាំងដល់ការបំពេញភារកិច្ចរបស់អង្គភាពទ័ពក៏ត្រូវផ្តន្ទាទោសជាទម្ងន់ដែរ ។ ជនណាដែលបានបង្ហាញដោយស្មោះត្រង់នូវសេចក្តីស្តាយក្រោយអំពីកំហុសរបស់ខ្លួន ហើយបានបង្កើតស្នាដៃណាមួយដើម្បីលុបលាងកំហុសនោះអាចត្រូវបានសន្តោសទោស ឬលើកលែងទោស ។

**មាត្រា ២** ការប្រឆាំងនឹងបញ្ជារបស់ថ្នាក់លើ ។

យោធាណា ដែលប្រឆាំងជាសាធារណៈនិងឋថ្នាក់លើទាក់ទងនិងករណីយកិច្ចយោធាសំខាន់ៗ ឬ មិនព្រមអនុវត្តបញ្ជា ឬ ប្រព្រឹត្តដោយចេតនា នឹងដោយផ្ទុយនឹងបញ្ជានេះត្រូវផ្តន្ទាទោសដាក់គុកពី៦ខែ ទៅ ៣ ឆ្នាំ ។

បើការប្រឆាំងនឹងបញ្ជា ធ្វើឡើងក្នុងពេលប្រយុទ្ធ ឬ ក៏អូសទាញជនច្រើនរូបនៅពេលជាមួយគ្នាអោយប្រឆាំងនឹងបញ្ជានោះបណ្តាលអោយមានផលអាក្រក់ជាទម្ងន់ ជនប្រព្រឹត្តបទល្មើសអាចត្រូវផ្តន្ទាទោសដាក់គុករហូតដល់ ១០ឆ្នាំ បើផលអាក្រក់មានលក្ខណៈធ្ងន់ធ្ងរជាពិសេស ជនប្រព្រឹត្តបទល្មើសអាចត្រូវផ្តន្ទាទោសដាក់គុករហូតដល់ ២០ ឆ្នាំ ឬ ដាក់គុកអស់មួយជីវិត ឬ ប្រហារជីវិត ។

**មាត្រា ៣** ការចុះចូលជាមួយខ្មាំង ។

យោធាណាចុះចូលជាមួយខ្មាំង ត្រូវផ្តន្ទាទោសដាក់គុកពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ ។ បើមនការញុះញង់ ឬ ជំរុញជនច្រើនរូបឱ្យចូលរួមប្រព្រឹត្តបទល្មើសនេះនៅពេលជាមួយគ្នា ឬ បើមានយកទាំងអាវុធនិងឯកសារសំខាន់ៗ ទៅជាមួយផងជនប្រព្រឹត្តបទល្មើស អាចត្រូវផ្តន្ទាទោសដាក់គុករហូតដល់១០ ឆ្នាំ ។ ប្រសិនបើអំពើប្រព្រឹត្តិនាំមកនូវផលអាក្រក់ធ្ងន់ធ្ងរជាពិសេសប្រព្រឹត្តបទល្មើស អាចត្រូវផ្តន្ទាទោសដាក់គុករហូតដល់ ២០ ឆ្នាំ ឬដាក់គុកអស់មួយជីវិត ឬ ប្រហារជីវិត ។

**មាត្រា ៤** ការលួច ការលក់ ការទិញ ការជួយលក់គ្រឿងអាវុធ បរិក្ខារ សម្លៀកបំពាក់ ឬ ប្រដាប់ប្រដាមានតម្លៃច្រើនផ្សេងទៀត របស់កងទ័ព ។

ជនណាលួច លក់ ទិញ ជួយលាក់គ្រឿងអាវុធ បរិក្ខា សម្លៀកបំពាក់ ប្រដាប់ប្រដាមានតម្លៃច្រើនផ្សេងទៀត របស់កងទ័ព ត្រូវផ្តន្ទាទោសដាក់គុកពី ១ ឆ្នាំ ទៅ ៥ ឆ្នាំ ក្នុងករណីធ្ងន់ធ្ងរ ជនប្រព្រឹត្តបទល្មើស អាចត្រូវផ្តន្ទាទោស រហូតដល់ ១០ ឆ្នាំ ។

ម៉្យាងទៀតជនប្រព្រឹត្តបទល្មើស អាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់រៀល ដែលនឹងកំណត់ទៅតាមលក្ខណៈ និង កម្រិតនៃការខូចខាត បណ្តាលមកពីអំពើល្មើស ។

**មាត្រា ៥** ការគម្រាមកំហែងភ្នាក់ងាររដ្ឋការ ។

យោធាណាដែលអាងលើមុខងាររបស់ខ្លួន អំណាចរបស់ខ្លួន លើកម្លាំងគ្នាច្រើនប្រដាប់អាវុធ ដើម្បីគម កំហែងអ្នករដ្ឋការណាមួយ ដែលកំពុងបំពេញភារកិច្ច បង្ខំអោយជននេះបោះបង់ករណីយកិច្ចរបស់ខ្លួន ឬឲ្យប្រព្រឹត្ត ផ្ទុយនឹងករណីយកិច្ចដែលជននោះត្រូវធ្វើត្រូវផ្តន្ទាទោសដាក់គុកពី ៦ ខែ ទៅ៣ឆ្នាំ បើអំពើប្រព្រឹត្តិនាំមកនូវផល អាក្រក់ធ្ងន់ធ្ងរ ជនប្រព្រឹត្តបទល្មើស អាចត្រូវផ្តន្ទាទោសដាក់គុករហូតដល់ ១០ ឆ្នាំ ។

**មាត្រា ៦** ការឃោសនាបំផ្លិចបំផ្លាញ ដើម្បីបំបែកបំបាក់កងទ័ព ។

ជនណាធ្វើការឃោសនាបំផ្លិចបំផ្លាញប្រឆាំងនឹងគោលនយោបាយ ប្រឆាំងនឹងនយោបាយជាក់ស្តែងរបស់ បដិវត្តន៍ ដើម្បីធ្វើឲ្យប៉ះពាល់ដល់ទឹកចិត្តកងទ័ព ដល់សាមគ្គីភាពនៃកងទ័ព ឬ ដើម្បីធ្វើឲ្យមានការបែកបាក់រវាងកង ទ័ព និងប្រជាជន រវាងកងទ័ព និងផ្នែកនានា ត្រូវផ្តន្ទាទោសដាក់គុកពី ៦ ខែ ទៅ៣ ឆ្នាំ ។

**មាត្រា ៧** ការវាយដំ និងការធ្វើឱ្យមានរបួស ។

ក្នុងការទាក់ទងរវាងអ្នកបញ្ជា និងអ្នកទទួលបញ្ជាយោធាណា ដែលប្រព្រឹត្តអំពើហឹង្សា ធ្វើឲ្យប៉ះពាល់ដល់រូប កាយរបស់កម្មាភិបាលថ្នាក់បញ្ជា ឬ កម្មាភិបាលថ្នាក់បញ្ជាណាដែលវាយដំ ឬ ធ្វើបាបអ្នកនៅក្រោមបង្គាប់របស់ខ្លួន ត្រូវផ្តន្ទាទោសដាក់គុកពី ៦ ខែ ទៅ៣ឆ្នាំ។ បើអំពើប្រព្រឹត្តបណ្តាលឱ្យមានរបួសធ្ងន់ ឬ បណ្តាលឲ្យស្លាប់ ជនប្រព្រឹត្ត បទល្មើសត្រូវផ្តន្ទាទោសពីបទវាយដំ និងធ្វើឲ្យគេមានរបួសដោយចេតនា ឬ ពីបទធ្វើមនុស្សឃាដ ។ ក្នុងករណីខាង ក្រោយនេះការផ្តន្ទាទោសត្រូវអនុវត្តតាមប្រការ ៧ នៃក្រឹត្យ-ច្បាប់ លេខ ០២ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨០ ។

**មាត្រា ៨** ការធ្វើអោយបែកការសម្ងាត់ និង ការធ្វើអោយបាត់ឯកសារសម្ងាត់ ។

យោធាណា ដែលផ្សាយការសម្ងាត់យោធាដល់អ្នកដទៃ ដែលជាជនគ្មានការទទួលខុសត្រូវក្នុងរឿងសម្ងាត់ នោះ ឬ យោធាណាធ្វើអោយបាត់ឯកសារសម្ងាត់ដោយការធ្វេសប្រហែស ត្រូវផ្តន្ទាទោសដាក់គុកពី៦ខែ ទៅ ៣ ឆ្នាំ។

**មាត្រា ៩** ការខ្វះស្មារតីទទួលខុសត្រូវ និងការមិនយកចិត្តទុកដាក់ក្នុងការងាររបស់ខ្លួនបណ្តលអោយមានផល អាក្រក់ធ្ងន់ធ្ងរ ។

យោធាណាខ្វះស្មារតីទទួលខុសត្រូវ ឬ មិនយកចិត្តទុកដាក់នឹងការងាររបស់ខ្លួនបណ្តាលអោយមានការខូច ខាតធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសដាក់គុកពី ៦ ខែ ទៅ ៣ឆ្នាំ ។ បើការខូចខាតនោះមានលក្ខណៈធ្ងន់ធ្ងរពិសេសជនប្រព្រឹត្ត បទល្មើសអាចត្រូវផ្តន្ទាទោសដាក់គុករហូតដល់ ១០ ឆ្នាំ ។

**មាត្រា ១០** ការគេចវេះពីបរិចារកិច្ចយោធា ។

យោធាណា ក្នុងគោលបំណងគេចពីបរិចារកិច្ចយោធាហើយដែលត្រូវបានអប់រំជាច្រើនលើកនៅតែមានៈរត់ ចោលជួរ ឬ ធ្វើអោយខ្លួនឯងមានរបួស ឬ មានជម្ងឺបណ្តាលអោយបាត់សប្បទាក្នុងការប្រយុទ្ធ និងក្នុងពលកម្ម ឬប្រើ ឧបាយកលទុច្ចរិតផ្សេងៗទៀត ដើម្បីគេចពីបរិចារកិច្ចយោធាត្រូវផ្តន្ទាទោសដាក់គុកពី ៦ ខែ ទៅ ៣ ឆ្នាំ ក្នុងករណី ធ្ងន់ធ្ងរ ដូចជាការជំរុញជនច្រើនរូបអោយរត់ចោលជួរ ការរត់ចោលជួរដោយយកទៅជាមួយនូវគ្រឿងអាវុធ បរិក្ខារសំ ខាន់ៗ របស់កងទ័ព ឬ ការប្រព្រឹត្តិបទល្មើលព្រហ្មទណ្ឌផ្សេងៗទៀត ជនប្រព្រឹត្តបទល្មើសអាចត្រូវផ្តន្ទាទោសដាក់គុក រហូតដល់ ៥ ឆ្នាំ ។

**មាត្រា ១១** បទល្មើសផ្សេងៗទៀត

យោធាណា ប្រព្រឹត្តបទល្មើស ព្រហ្មទណ្ឌទាំងឡាយដែលមានចែងក្នុងក្រឹត្យ-ច្បាប់ លេខ ០២ ក-ច ចុះថ្ងៃទី ១៥ ឧសភា ឆ្នាំ១៩៨០ ត្រូវផ្តន្ទាទោសតាមទណ្ឌកម្ម ដែលមានកំណត់ក្នុងក្រឹត្យ-ច្បាប់ លេខ ០២ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨០ នេះ ។

**មាត្រា ១២** ក្រឹត្យ -ច្បាប់នេះត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយ ដែលបានកើតឡើងតាំងពីថ្ងៃ៧ មករា ឆ្នាំ ១៩៧៩ ហើយដែលពុំទាន់បានដាក់ជំនុំជម្រះនៅឡើយ ។

**មាត្រា ១៣** រដ្ឋមន្ត្រីក្រសួងការពារប្រទេស រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលអនុវត្តក្រឹត្យ-ច្បាប់នេះ តាមភារកិច្ចរៀងៗខ្លួន។

ធ្វើនៅភ្នំពេញ,ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៨១

ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

**ហេង សំរិន**

បានទទួលទអនុវត្ត

ជ.ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ចាន់ ស៊ី**